# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ១៥១ ក.ធ.សក

## សេចក្ដីសំរេច

ស្ដីពីការអនុញ្ញាតឱ្យបង្កើតវត្តថ្មីឈ្មោះថា " នួនមុនីសាមគ្គីសុខារាម "
នៃគណៈមហានិកាយ ភូមិបឹងក្រទីប ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង

### រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១១៩៨ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា.

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី.

-បានឃើញព្រះរាជក្រមលេខ នស.រកម០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងធម្មការ និងសាសនា.

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងធម្មការ និងសាសនា.

-យោងតាមចំណារឯកភាពរបស់អភិបាល ខេត្ត ព្រៃវែង លេខ ១២៩ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០២.

-យោងតាមចំណាររបស់ប្រធានមន្ទីរធម្មការ និងសាសនា ខេត្តព្រៃវែង លេខ ៦២ មធស.៣រ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០២.

-យោងតាមចំណាររបស់អភិបាលស្រុកកំពង់ត្របែក លេខ គ្មាន ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០២.

-តាមសំណើសុំរបស់ ចៅអធិការ និងលោកអាចារ្យវត្ត " នួនមុនីសាមគ្គីសុខារាម " ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០២.

### សំរេច

**ប្រការមួយ:** អនុញ្ញាតឱ្យបង្កើតវត្តថ្មី ឈ្មោះ " នួនមុនីសាមគ្គីសុខារាម " នៃគណៈមហានិកាយ ដែលស្ថិតនៅក្នុង ភូមិបឹងក្រទីប ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដោយរក្សានូវក្បាច់រចនា ជាប្រពៃណីរបស់ជាតិ ។

**ប្រការពីរ :** វត្តថ្មីនេះ ត្រូវដាក់ប្រគេនព្រះសង្ឃ និងជូនពុទ្ធបរិស័ទគោរពប្រតិបត្តិ និងធ្វើបុណ្យទានឱ្យបានត្រឹមត្រូវ តាមពុទ្ធបញ្ញត្តិ និងពុទ្ធានុញ្ញាត និងប្រពៃណីពុទ្ធសាសនា ព្រមទាំងច្បាប់របស់រដ្ឋឱ្យបានល្អ ប្រសើរ និងរីកចំរើន ។

**ប្រការបី :** ខុទ្ទកាល័យ អគ្គនាយកដ្ឋានធម្មការ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មន្ទីរធម្មការ និងសាសនា ខេត្តព្រៃវែង អង្គភាពពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ និងអាចារ្យ- គណៈកម្មការវត្ត ត្រូវអនុវត្តសេចក្ដីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ ២០០២

**រដ្ឋមន្ត្រី**

ជា សាវឿន

**ចម្លងជូន:**

-សម្ដេចព្រះសង្ឃរាជគណៈមហានិកាយ

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

" ដើម្បីថ្វាយ-ជូនជ្រាប "

-រាជកិច្ច " ដើម្បីចុះផ្សាយ "

-សាលាខេត្តព្រៃវែង

-អភិបាលស្រុកកំពង់ត្របែក

-ដូចប្រការបី

" ដើម្បីសហការអនុវត្ត "

ឯកសារ-កាលប្បវត្តិ